អង្គការអភិវឌ្ឍន៍សំលេងសហគមន៍

**គម្រោង៖** បង្កើនជីវភាពរស់នៅរបស់សហគមន៍ តាមរយៈអេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ

# **របាយការណ៍ករណីសិក្សា**

## **សហគមន៍អេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ – បុរសក្នុងសហគមន៍**

១. សេចក្តីផ្តើម

សហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ថ្ម ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ ដោយមានការគាំទ្រពីមន្ទីរ និងក្រសួងបរិស្ថាន។ សហគមន៍មានផ្ទៃដី ៥០៦ ហិកតា មានគណៈកម្មការ ៩ រូប (ស្រី ៣ រូប) និងមានអ្នកទទួលផលសរុប ៦២៥ នាក់។ ប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ចិញ្ចឹមសត្វ និងប្រមូលអនុផលព្រៃឈើ ខណៈមួយចំនួនធ្វើការចំណាកស្រុក។

សហគមន៍កំពុងប្រឈមមុខនឹងបញ្ហាខ្វះធនធានថវិកា ដៃគូអភិវឌ្ឍន៍ និងសមត្ថភាពបច្ចេកទេស។ បន្ថែមពីនេះ ភូមិជីពូក និងភូមិងយ រងផលប៉ះពាល់ពីរាំងស្ងួត និងការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់ដល់ទិន្នផលកសិកម្ម និងជីវភាពរស់នៅ បង្កើនហានិភ័យនៃសកម្មភាពខុសច្បាប់លើធនធានធម្មជាតិ។

## **២.ព័ត៌មានទូទៅអំពីលោក ជីវ សុក មុនចូលរួមជាមួយគម្រោង GEF**

លោក ជីវ សុក អាយុ ៣១ឆ្នាំ រស់នៅភូមិជីពូក ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ លោក ជីវ សុក មានមុខរបរជាកសិករ លោកក្លាយជាសមាជិកគណៈកម្មការតាំងពីឆ្នាំ២០១៦ ដោយការបោះឆ្នោតពីប្រជាពលរដ្ឋក្នុងសហគមន៍។ មូលហេតុដែលលោក ជីវ សុក សម្រេចចិត្តចូលរួមជាគណៈកម្មការសហគមន៍ព្រៃធំអន្លង់ថ្ម ពីព្រោះលោក ចូលចិត្តការងារសហគមន៍ ស្រឡាញ់បរិស្ថាន ចង់ការពារព្រៃឈើ ចង់អភិរក្សធនធានធម្មជាតិ ដូចជា សត្វក្ងោក ឈ្លូស និងសត្វព្រៃដទៃទៀតអោយបានគង់វង្ស មិនតែប៉ុណ្ណោះលោក ក៏ចង់បានប្រាក់ចំណូលបន្ថែមពីការផ្តល់សេវាដល់ភ្ញៀវទេសចរណ៍ផងដែរ។ នៅពេលនោះ លោក ជីវ សុក មានការយល់ដឹងតិចតួចណាស់អំពីអត្ថប្រយោជន៍នៃការការពារធនធានធម្មជាតិ និងការ

បម្រែបម្រួលអាកាសធាតុ ការចូលរួមរបស់លោកជាមួយសហគមន៍ក៏មានកំរិតដែរពីព្រោះលោកត្រូវរវល់រកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារតាមរយៈធ្វើស្រែចំការតិចតួច។ នៅពេលដែលប្រជុំជាមួយសមាជិកសហគមន៍ និងប្រជាពលរដ្ឋម្តងៗ លោក មិនដែលហាននិយាយជាមួយពួកគាត់ទេព្រោះមានភាពអៀនខ្មាស់ ភ័យ និងមិនមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការនិយាយ។



## ៣.ក្នុងអំឡុងពេលចូលរួមសកម្មភាពជាមួយគម្រោង GEF

នៅក្នុងឆ្នាំ ២០២៤ សហគមន៍ព្រៃធំអន្លង់ថ្ម ទទួលបានការគាំទ្រពីគម្រោងកម្មវិធី GEF ដែលជាឱកាសមួយដ៏ល្អរបស់លោកក្នុងការពង្រឹងសមត្ថភាព ជំនាញ ភាពជាអ្នកដឹកនាំ ការបម្រែបម្រួលអាកាសធាតុ ជំនាញនៃការសរសេររបាយការណ៍ ជំនាញការគ្រប់គ្រងប្រាក់សន្សំ ជាពិសេសជាងនេះទៅទៀតលោកក៏បានការពង្រឹងសមត្ថភាពបន្ថែមទៀតតាមរយៈការចូលរួមធ្វើទស្សនៈកិច្ចសិក្សាពីសហគមន៍ផ្សេង

ទៀតដែលអនុវត្តការងារលើវិស័យស្រដៀងគ្នា។ មិនត្រឹមតែទទួលបានការបណ្តុះបណ្តាលសមត្ថភាពប៉ុណ្ណោះទេ លោកជីវ សុក បានចូលរួមអនុវត្តសកម្មភាពយ៉ាងសកម្មជាច្រើនទៀតដូចជា ៖ ចុះល្បាត និងចាប់បទល្មើសកាប់ឈើ និងដឹកឈើ បទល្មើសបរបាញ់ និងដាក់អន្ទាក់សត្វ ចូលរួមដាំកូនឈើ ចូលរួមធ្វើផ្លូវការពារភ្លើងឆេះព្រៃ និងផ្លូវសម្រាប់ភ្ញៀវទេសចរណ៍ជិះកង់ទស្សនាក្នុងព្រៃសហគមន៍ សំអាតផ្លូវ និងត្រួសត្រាយផ្លូវសម្រាប់ភ្ញៀវទេសចរណ៍ដើរទស្សនាក្នុងព្រៃសហគមន៍ និងចូលរួមផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍ អំពីការបម្រែប្រួលអាកាសធាតុ និងសារៈប្រយោជន៍នៃការអភិរក្សធនធានធម្មជាតិ។ មិនតែប៉ណ្ណោះ លោក ជីវ សុក ក៏បានចូលរួមផងដែរជាមួយក្រុមសន្សំប្រាក់សហគមន៍។

## ៤. ការប្រែប្រួលបន្ទាប់ពីលោក ជីវ សុក បានចូលរួមជាមួយគម្រោង GEF

តាមរយៈការទទួលបានការកសាងសម្ថភាពចំណេះដឹង និងជំនាញមួយចំនួនដែលបានគាំទ្រដោយគម្រោង GEF លោក ជីវ សុក មានការរីកចម្រើនជាច្រើនទៅលើ សមត្ថភាព និងទំនុកចិត្តក្នុងការបន្តការផ្សព្វផ្សាយអំពីការបម្រែបម្រួលអាកាសធាតុដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ មានជំនាញក្នុងការសរសេររបាយការណ៍វឌ្ឍនភាពរបស់សហគមន៍បានល្អប្រសើរ លោកមានភាពសកម្មជាងមុនក្នុងការអភិរក្សធនធានធម្មជាតិ ចំណែកជីវភាពគ្រួសារប្រសើរឡើងពី៣០% ទៅ៧០% តាមរយៈទទួលបានភាគលាភពីការសន្សំប្រាក់ និងការចិញ្ចឹមមាន់ គោ និងសេវាដឹកភ្ញៀវដើរទស្សនាព្រៃសហគមន៍។

**រូបភាពសកម្មភាពលោក ជីវ សុក ចូលរួមក្នុងសហគមន៍**





## សម្រង់សម្តីលោក ជីវ សុក:

"គម្រោងនេះបានបង្កើនទំនុកចិត្ត និងជីវភាពគ្រួសារខ្ញុំ ហើយធ្វើឱ្យខ្ញុំមានមោទនភាពក្នុងការការពារព្រៃឈើសហគមន៍របស់យើង។"

## សំណូមពរ និងអនុសាសន៍

ដោយសារតែសមត្ថភាពសមាជិកគណៈកម្មការនៅមានកំរិត និងដំណើការសហគមន៍ព្រៃធំអន្លង់ថ្មមិនទាន់បានល្អ លោក ជីវ សុក ស្នើសុំការគាំទ្របន្តពីម្ចាស់ជំនួយរបស់គម្រោង GEF ដើម្បីពង្រឹងសមត្ថភាពគណៈកម្មការ និងសមាជិកសហគមន៍បន្ថែមទៀត ជាពិសេសលើការគ្រប់គ្រងធនធានធម្មជាតិ និងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

**រៀបចំដោយ៖ លោកស្រី ជួប ចន្ទី** ក្រុមអ្នកវាយតម្លៃឯករាជ្យ ART